**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តត្បូងឃ្មុំ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ២៨
ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌ (ប្ដឹងទាស់)
លេខៈ៤៩១ "ផ"
ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តត្បូងឃ្មុំ

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ម៉ោង ៨ព្រឹក
និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ម៉ោង ៩ព្រឹក
ដែលមានសមាសភាពដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តត្បូងឃ្មុំ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តត្បូងឃ្មុំ

***ដើម្បីជំនុំជម្រះលើបណ្ដឹងទាស់***

ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ២៨ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទៈ

-ឈ្មោះ [redacted] គង់ ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] មិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី២។ ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ១នាក់ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" ទោសពីមុនគ្មាន។

(ដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនលេខៈ៧៧៩ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២)

ជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

## អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ

កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខួច ភេទប្រុស អាយុ៤១ឆ្នាំ នៅចំណុចភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់។ ជនជាប់ចោទសារភាពថាថ្នាំញៀនខាងលើខ្លួនទិញពីឈ្មោះ [redacted] គង់ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ១០ អយ.ឃ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ។



ស្កេនជាមួយ CamScanner

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ១៥៣ អយ.យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ៤៩៥ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ និងឯកសារនានាក្នុងសំណុំរឿង។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ៣២០ "ឆ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ។

**ដំណើរការនៃកិច្ចពិភាក្សាដេញដោលនាពេលសវនាការមានដូចតទៅ៖**

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] គង់ បានឆ្លើយនៅសវនាការថាៈ ខ្លួនស្គាល់ឈ្មោះ [redacted] សុខខួច ដែរ ព្រោះពីមុនមកធ្លាប់ទៅនៅផ្ទះគាត់តាំងពីតូចមកម្ល៉េះ។ ចំពោះអង្គហេតុដែលឈ្មោះ [redacted] សុខខួច ឆ្លើយថា បានទិញថ្នាំញៀនពីខ្លួន នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ នោះ គឺខ្លួនមិនទទួលស្គាល់នោះទេ ព្រោះពេលនោះ គឺខ្លួនកំពុងតែនៅស្រែសៀមឯណោះ ដោយមិនបានទៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ នោះទេ។ ខ្លួនធ្លាប់ជាប់ពន្ធនាគារនៅឆ្នាំ២០១៨ នឹងចេញមកវិញនៅឆ្នាំ២០១៩ ពីបទ ជួញដូរគ្រឿងញៀនផងដែរ។ កាលអំឡុងខែធ្នូ ឆ្នាំ២០២១ ខ្លួនធ្លាប់បានជួបឈ្មោះ [redacted] សុខខួច នៅកន្លែងចាក់អាប៉ោងម្តងដែរ ប៉ុន្តែខ្លួនពុំបានលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សុខខួច នោះទេ។ ខ្លួនពុំដែលប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ [redacted] សុខខួច នោះទេ។ ខ្លួនមិនដឹងថា គេចាប់ខ្លួនឈ្មោះ [redacted] សុខខួច ពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀននោះទេ។ ក្រោយពេលដែលខ្លួនចេញពីពន្ធនាគារ គឺខ្លួនពុំដែលជួញដូរ ឬប្រើប្រាស់គ្រឿងញៀននោះទេ។ ខ្លួនធ្លាប់ជួបឈ្មោះ [redacted] សុខខួច បានម្តងក្រោយចេញពីគុក នៅកន្លែងគេលេងអាប៉ោង។ ខ្លួនជាអ្នកលក់ត្រីនៅស្រែសៀម ហើយពេលខ្លួនរៀបការ គឺពុំបានប្រាប់គាត់នោះទេ។ ពេលខ្លួនជួបឈ្មោះ [redacted] សុខខួច នៅកន្លែងគេលេងអាប៉ោង គឺខ្លួនពុំបាននិយាយគ្នានោះទេ ព្រោះពេលនោះឈ្មោះ [redacted] សុខខួច កំពុងតែរវល់ផឹក។ ពេលខ្លួននៅជាមួយគាត់ គឺគាត់មិនដែលស្គាល់ឈ្មោះឪពុកម្តាយខ្លួននោះទេ ហើយក៏ពុំដែលស្គាល់នាមត្រកូលខ្លួនដែរ។ សុំជួយរកយុត្តិធម៌ដល់ខ្លួនផង ព្រោះខ្លួនពុំបានប្រព្រឹត្តខុសនោះទេ សូមតុលាការលើកលែងការចោទប្រកាន់ដល់ខ្លួនផង។

-តាមចម្លើយសាក្សីឈ្មោះ [redacted] សុខខួច បានឆ្លើយនៅសវនាការថាៈ ឈ្មោះ [redacted] គង់ នៅអង្គសវនាការនាពេលនេះ ខ្លួនពុំដែលស្គាល់នោះទេ។ ឈ្មោះ គង់ ដែលខ្លួនធ្លាប់ទិញគ្រឿងញៀនកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២១ នោះ គឺពុំមែនឈ្មោះ [redacted] គង់ មានរូបរាងដូចនៅក្នុងអង្គសវនាការនេះទេ។ ខ្លួនពុំដែលស្គាល់ ឬជក់ថ្នាំញៀនជាមួយឈ្មោះ [redacted] គង់ ក្នុងអង្គសវនាការនេះទេ ចំណែកឈ្មោះ គង់ ដែលខ្លួនទិញថ្នាំញៀននោះ គឺមាឌធំ ខ្ពស់ ខ្មៅស្រអែម សក់វែងចំហៀង។ ខ្លួនពុំធ្លាប់ទៅទិញថ្នាំញៀនជាមួយឈ្មោះ [redacted] គង់ ក្នុងអង្គសវនាការនេះទេ គឺខ្លួនធ្លាប់តែទៅទិញថ្នាំញៀនជាមួយឈ្មោះ គង់ ម្នាក់ទៀត ហើយឈ្មោះ គង់ ដែលខ្លួនទិញថ្នាំញៀននៅកន្លែងគេលេងអាប៉ោងនោះ គឺខ្លួនមិនដឹងថាគាត់នៅម្តុំណានោះទេ ព្រោះខ្លួនពុំស្គាល់ស្រុកកំណើតនោះទេ។ ខ្លួនទិញថ្នាំញៀនពីឈ្មោះ គង់ នៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ហើយខ្លួនពុំដែលស្គាល់ត្រកូលឈ្មោះ គង់ នោះទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សុខខួច បានឆ្លើយនៅសវនាការលើកមុនថាៈ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២១ ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ [redacted] គង់ នៅភូមិទួលឃ្លាំង តម្លៃ២០.០០០ (ពីរម៉ឺន) រៀល ហើយបន្ទាប់ពីទិញថ្នាំញៀនបានរួចហើយ ខ្លួនក៏ឡើងជិះឡានដឹកគោត្រឡប់មកផ្ទះវិញ ហើយក៏ត្រូវបានសមត្ថកិច្ចហៅឈប់ត្រួតពិនិត្យឆែកឆេរឃើញថ្នាំញៀននៅក្នុងហោប៉ៅខោរបស់ខ្លួនតែម្តង។ ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] គង់ បានចំនួន២ដងមកហើយ ដោយទិញលើកទី១ តម្លៃ ៥០.០០០ (ប្រាំម៉ឺន) រៀល ដើម្បីយកមកជក់ ហើយឈ្មោះ [redacted] គង់ មានរាងខ្ពស់ មាឌធំ ខ្មៅស្រអែម។

**សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ**



ស្កេនជាមួយ CamScanner

34/3

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ និងឯកសារផ្សេងៗមាននៅក្នុងសំណុំរឿង និងរបាយការណ៍របស់នគរបាលយុត្តិធម៌ នៃអធិការដ្ឋាននគរបាលស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ព្រមទាំងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងគឺអាចឱ្យអយ្យការជឿជាក់បានថា៖ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខួច ភេទប្រុស អាយុ៤១ឆ្នាំ នៅចំណុចភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់។ ជនជាប់ចោទសារភាពថា ថ្នាំញៀនខាងលើខ្លួនទិញពីឈ្មោះ [redacted] គង់ ភេទប្រុស អាយុ ២៨ឆ្នាំ។ ហេតុដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់លើឈ្មោះ [redacted] គង់ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងប្តឹងសុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ៖៣២០ "ធ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការដដែល។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ បានសំណូមពរឱ្យតុលាការជួយលើកលែងទោសដល់ខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តអំពើល្មើសច្បាប់ដូចការចោទប្រកាន់នោះទេ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ ។

-ក្រោយពីបានស្តាប់ចម្លើយសាក្សីរបស់ជនជាប់ចោទឈ្មោះ [redacted] សុខខួច។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុខខួច (សវនាការលើកមុន) ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សំដីជាសំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ ។

-ក្រោយពីបានពិនិត្យលទ្ធផលកោសលវិច័យគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

-ក្រោយពីបានពិនិត្យឯកសារដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ។

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារត្រឹមត្រូវហើយ ។

-ក្រោយពីបានស្តាប់អំណានឯកសារនានាដែលមាននៅក្នុងសំណុំរឿង ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ហើយ ។

## សំអាងហេតុ

១-កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខួច ភេទប្រុស អាយុ៤១ឆ្នាំ នៅចំណុចភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់។ ជនជាប់ចោទសារភាពថាថ្នាំញៀនខាងលើខ្លួនទិញពីឈ្មោះ [redacted] គង់ ភេទប្រុស អាយុ ២៨ឆ្នាំ ប្រាកដមែន។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ នាពេលសវនាការបានឆ្លើយថា៖ខ្លួនស្គាល់ឈ្មោះ [redacted] សុខខួច ដែរ ព្រោះពីមុនមកធ្លាប់ទៅនៅផ្ទះគាត់តាំងពីតូចមកម្ល៉េះ។ ចំពោះអង្គហេតុដែលឈ្មោះ [redacted] សុខខួច ឆ្លើយថា បានទិញថ្នាំញៀនពីខ្លួននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ នោះ គឺខ្លួនមិនទទួលស្គាល់នោះទេ ព្រោះពេលនោះ គឺខ្លួនកំពុងតែនៅស្រែសៀមឯណោះ ដោយមិនបានទៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ នោះទេ។ ខ្លួនធ្លាប់ជាប់ពន្ធនាគារនៅឆ្នាំ២០១៨ នឹងចេញមកវិញនៅឆ្នាំ២០១៩ ពីបទ ជួញដូរគ្រឿងញៀន ផងដែរ។ កាលអំឡុងខែធ្នូ ឆ្នាំ២០២១ ខ្លួនធ្លាប់បានជួបឈ្មោះ [redacted] សុខខួច នៅកន្លែងចាក់អាប៉ោងម្តងដែរ ប៉ុន្តែខ្លួនពុំបានលក់ថ្នាំញៀនឱ្យឈ្មោះ [redacted] សុខខួច នោះទេ។ ខ្លួនពុំដែលប្រើប្រាស់គ្រឿងញៀនជាមួយឈ្មោះ [redacted] សុខខួច នោះទេ។ ខ្លួនមិនដឹងថាគេចាប់ខ្លួនឈ្មោះ [redacted] សុខខួច ពីបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន នោះទេ។



ស្កេនជាមួយ CamScanner

ក្រោយពេលដែលខ្លួនចេញពីពន្ធនាគារ គឺខ្លួនពុំដែលជួញដូរ ឬប្រើប្រាស់គ្រឿងញៀន ទេ។ ខ្លួនធ្លាប់ជួបឈ្មោះ [redacted] សុខខូច បានម្តងក្រោយចេញពីគុក នៅកន្លែងគេលេងអាប៉ោង។ ខ្លួនជាអ្នកលក់ត្រីនៅស្រែសៀម ហើយពេលខ្លួនរៀបការគឺពុំបានប្រាប់គាត់នោះទេ។ ពេលខ្លួនជួបឈ្មោះ [redacted] សុខខូច នៅកន្លែងគេលេងអាប៉ោង គឺខ្លួនពុំបាននិយាយគ្នានោះទេ ព្រោះពេលនោះឈ្មោះ [redacted] សុខខូច កំពុងតែរវល់ផឹក។ ពេលខ្លួននៅជាមួយគាត់គឺគាត់មិនដែលស្គាល់ឈ្មោះឪពុកម្តាយខ្លួននោះទេ ហើយក៏ពុំដែលស្គាល់នាមត្រកូលខ្លួនដែរ។ សុំជួយរកយុត្តិធម៌ដល់ខ្លួនផង ព្រោះខ្លួនពុំបានប្រព្រឹត្តខុសនោះទេ។ តុលាការយល់ឃើញថា ចំពោះចម្លើយបដិសេធទាំងស្រុងរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ ខាងលើនេះ គឺជាចម្លើយដែលមិនអាចឱ្យតុលាការជឿជាក់បាននោះទេ ព្រោះចម្លើយនេះមិនមានភាពស៊ីសង្វាក់ជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ស្រុកអូររាំងឪ និងមិនមានភាពស៊ីសង្វាក់ជាមួយសក្ខីកម្ម ព្រមទាំងភស្តុតាង និងឯកសារនានាដែលមានក្នុងសំណុំរឿងបានបញ្ជាក់ថាៈ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខខូច ភេទប្រុស អាយុ៤១ឆ្នាំ នៅចំណុចភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់។ ជនជាប់ចោទឈ្មោះ [redacted] សុខខូច បានសារភាពថា ថ្នាំញៀនខាងលើខ្លួនទិញពីឈ្មោះ [redacted] គង់ ភេទប្រុស អាយុ២៨ឆ្នាំ ប្រាកដមែន។ ម្យ៉ាងវិញទៀតចំពោះចម្លើយរបស់ [redacted] សុខខូច ដែលបានឆ្លើយចំនួនពីរលើកក្នុងអង្គសវនាការកន្លងមកនេះ គឺមានភាពផ្ទុយគ្នាស្រឡះ ដែលមិនអាចជាមូលដ្ឋានសម្រាប់តុលាការលើកមកពិចារណាបាននោះទេ ព្រោះចម្លើយនេះមានភាពមិនប្រក្រតីជាច្រើនចំពោះអង្គហេតុ ហើយជននេះបានកែប្រែចម្លើយរបស់ខ្លួនផ្ទុយពីការពិតដើម្បីដោះបន្ទុកលើឈ្មោះ [redacted] គង់ ដែលជាបក្ខពួករបស់ខ្លួន ហើយនៅក្នុងសវនាការឈ្មោះ [redacted] គង់ ឆ្លើយថា មិនដែលជួបឈ្មោះ [redacted] សុខខូច នោះទេ ព្រោះឈប់រស់នៅជាមួយឈ្មោះ [redacted] សុខខូចជាយូឆ្នាំមកហើយ ប៉ុន្តែជាក់ស្តែង កាលអំឡុងខែធ្នូ ឆ្នាំ២០២១ បន្ទាប់ពីចេញពីពន្ធនាគារ គឺឈ្មោះ [redacted] គង់ បានសារភាពថាខ្លួនធ្លាប់បានជួបឈ្មោះ [redacted] សុខខូច នៅកន្លែងចាក់អាប៉ោងម្តងដែរ ដែលចំណុចនេះមានន័យថាជននេះពិតជានៅមានទំនាក់ទំនងជាមួយឈ្មោះ [redacted] សុខខូច និងបានលក់ថ្នាំញៀនទៅឱ្យជននេះប្រាកដមែន ចំណែកចម្លើយរបស់ឈ្មោះ [redacted] សុខខូច គឺមានភាពមិនច្បាស់លាស់ និងមិនមានភាពប្រាកដប្រជានោះទេ ដោយតុលាការបានពិនិត្យចម្លើយរបស់ជននេះទាំងពីរលើករួចមកឃើញថា ជននេះព្យាយាមឆ្លើយដើម្បីដោះបន្ទុកឱ្យឈ្មោះ [redacted] គង់ តែប៉ុណ្ណោះ ដោយពុំបានបង្ហាញឱ្យឃើញនូវការពិតចំពោះអំពើល្មើសរបស់ឈ្មោះ [redacted] គង់នោះឡើយ។ ជាមួយគ្នានេះដែរ តាមរយៈការផ្ទៀងផ្ទាត់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងឯកសារនានាក្នុងសំណុំរឿងឃើញថា ពិតជាមានអំពើៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបង្កឡើយដោយឈ្មោះ [redacted] គង់ ប្រាកដមែន ហើយទង្វើនេះមានភាពស៊ីសង្វាក់គ្នាជាមួយរបាយការណ៍របស់នគរបាលយុត្តិធម៌ស្រុកអូររាំងឪផងដែរ។

៣-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការដែលបានលើកឡើងថា រក្សាការចោទប្រកាន់លើឈ្មោះ [redacted] គង់ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរទុកដដែល និងស្នើសុំឱ្យតុលាការតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៣២០ "ធ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការដដែល។ ចំពោះការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ស្របតាមសក្ខីកម្មទាំងអស់ ព្រមទាំងឯកសារផ្សេងៗទៀតក្នុងសំណុំរឿង ដែលអាចឱ្យតុលាការពិចារណាបាន ។

៤-ផ្អែកតាមសំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] គង់ នាពេលសវនាការ បានសំណូមពរឱ្យតុលាការជួយលើកលែងទោសដល់ខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។ ចំពោះ



ស្កេនជាមួយ CamScanner

សំណូមពរចុងក្រោយរបស់ជនជាប់ចោទរូបនេះ តុលាការនឹងលើកយកមកពិចារណាតាមផ្លូវច្បាប់ ដោយផ្អែកលើភស្តុតាង និងសក្ខីកម្មផ្សេងៗ ដែលមានក្នុងសំណុំរឿង។

៥-អំពើរបស់ជនជាប់ចោទខាងលើដែលបាន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតជាបានធ្វើឱ្យប៉ះពាល់សុខភាពខ្លួនឯង និងសុខភាពរបស់អ្នកដទៃជាខ្លាំង ជាពិសេសគឺបានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គមដែលច្បាប់បានបញ្ញត្តិផ្តន្ទាទោស។ ជនឈ្មោះ [redacted] គង់ នៅតែឆ្លើយបដិសេធ មិនទទួលស្គាល់ការពិតទោះបីជាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ហើយក្តី ពោលគឺមានភស្តុតាងដាក់បន្ទុកលើជននេះដូចមាននៅក្នុងសាលក្រមលេខៈ៣២០ "ឆ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំដដែល។ ដូចនេះតុលាការនឹងសម្រេចពិចារណាផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ស្របតាមអង្គហេតុ និងព្យសនកម្មដែលបានកើតឡើងជាក់ស្តែង។

៦-មានភស្តុតាង,ពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ៖

-ឈ្មោះ [redacted] គង់ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ទីលំនៅបច្ចុប្បន្ន [redacted] មិនពិតប្រាកដ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៦។ ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" ទោសពីមុនគ្មាន។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិទួលឃ្លាំង ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>ហេតុដូច្នេះសម្រេច</u>

១_ទទួលយកបណ្តឹងទាស់នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៣២០ "ឆ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២_តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៣២០ "ឆ" ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តត្បូងឃ្មុំ ទុកជាបានការទាំងមូលដដែល។

៣_សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] គង់។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ថ្ងៃអង្គារ ៤រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ខេត្តត្បូងឃ្មុំ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រាៈ [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រាៈ [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ៤រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ខេត្តត្បូងឃ្មុំ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

**ក្រឡាបញ្ជី**



[redacted] [redacted]